雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.196

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

klunerlight@163.com
yunnangateway.com
Follow Amazing Yunnan on Facebook

ឆ្នាំទី27 លេខ8045 ថ្ងៃសុក្រ ទី04 ខែតុលា ឆ្នាំ2019

## "បទពិសោធន៍របស់ចិនមានសារសំខាន់សម្រាប់មនុស្សជាតិទាំងមូល"

គំនូរដ៏ស្រស់ស្អាតមួយផ្ទាំងឈ្មោះថា "ពិភពលោកចម្រុះពណ៌ប្រកបដោយកម្លាំងរស់រវើក" បានបង្ហាញពីទិដ្ឋភាពមួយដែលមានមុខញញឹមរបស់មនុស្សច្រើនមានអាយុខុសគ្នាមកពីប្រទេសខុសគ្នានិងមានសម្បុរពណ៌ខុសគ្នា ហើយប្រកបជារូបរាង នៃផែនទីពិភពលោក ។ គំនូរនេះបានបញ្ជាំងឱ្យឃើញពីក្តីសង្ឃឹមនៃជីវភាពដ៏ល្អបវររបស់មនុស្សជាតិ ។ ពិព័រណ៍គំនូរអន្តរជាតិមួយកំពុងត្រូវរៀបចំនៅក្នុងសារមន្ទីរវិចិត្រសិល្បៈចិនក្រោមប្រធានបទ"ពិភពលោកចម្រុះពណ៌និងជោគវាសនារួម"។ស្នាដៃរបស់វិចិត្រករ ៥៩៥រូប ដែលមកពីប្រទេសចំនួន ១១៣ បានត្រូវដាក់តាំងបង្ហាញជូនសាធារណជនក្នុងពិព័រណ៍នេះ ។ ក្នុងឱកាសនៃការអបអរសាទរខួបលើកទី៧០ឆ្នាំ នៃការបង្កើតប្រទេសចិនថ្មីនេះ គំនូរស្អាតៗ ទាំងនោះក៏អាចបង្ហាញឱ្យឃើញពីការប្រែប្រួលនៃប្រទេសចិន និងពិភពលោកក្នុងរយៈពេល៧០ឆ្នាំកន្លងទៅ ។



នាវាខ្នាតធំចូល ចតជាលើកទី១ នៅផែក្រុមហ៊ុន COSCO SHIPPING LINES ក្នុងក្រុងអាប៊ុយដាប៊ី។

នៅពេលនិយាយចំពោះប្រវត្តិសាស្ត្ររយៈពេល៧០ឆ្នាំនៃប្រទេសចិនថ្មី ឯកឧត្តម ស៊ី ជីនភីង ប្រធានាធិបតីចិនបានសង្កត់ធ្ងន់ថា ទោះជាក្នុងប្រវត្តិសាស្ត្រនៃជនជាតិចិនឬក្នុងប្រវត្តិសាស្ត្រពិភពលោកនេះសុទ្ធតែជាកំណាព្យប្រវត្តិសាស្ត្រអំពីកិច្ចឧស្សាហ៍ព្យាយាមមួយដែលអាចធ្វើឱ្យពិភពលោករំភើបចិត្តយ៉ាងខ្លាំង ។ ក្នុងរយៈពេល៧០ឆ្នាំកន្លងទៅ ប្រជាជនចិនឧស្សាហ៍ព្យាយាមជាប់រហូតដើម្បីដើរឆ្ពោះទៅកាន់គោលដៅនៃការកសាងប្រទេសសង្គមនិយមទំនើបភាវូបនីយកម្មដ៏ខ្លាំងក្លាដោយផ្អែកលើកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនហើយក៏បានផ្តល់ក្តីប្រាជ្ញាចិនគម្រោងចិននិងកម្លាំងចិនដើម្បីរួមចំណែកក្នុងការថែរក្សាសន្តិភាពនិងជំរុញការអភិវឌ្ឍនៃពិភពលោក ។

លោកសេដ្ឋវិទូ Coase បានបញ្ជាក់ថា "ខ្ញុំយល់ដឹងច្បាស់អំពីអនាគតដ៏ភ្លឺស្វាងនៃប្រទេសចិនហើយដឹងថាកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសចិន គឺជាកិច្ចខិតខំប្រឹងប្រែងរបស់មនុស្សជាតិទាំងមូល ។ បទពិសោធន៍ចិនមានសារសំខាន់ណាស់សម្រាប់មនុស្សជាតិទាំងមូល។"នេះបានបង្ហាញពីសារសំខាន់ នៃការអភិវឌ្ឍរបស់ប្រទេសចិនសម្រាប់ពិភពលោក ។ បច្ចុប្បន្នប្រទេសចិនបានក្លាយទៅជាប្រទេសនាំមុខគេក្នុងការសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៃអង្គការសហប្រជាជាតិ ។ ក្រោយពីអនុវត្តន៍គោលនយោបាយកែទម្រង់និងបើកចំហរៀងមក ប្រទេសចិនបានជួយប្រជាជនចិនជាង៧០០លាននាក់ជៀសផុតពីភាពក្រីក្រនិងបានរួមវិភាគទានជាង៧០ភាគរយ ក្នុងការកាត់បន្ថយភាពក្រីក្រលើពិភពលោក ។ ក្នុងឱកាសកិច្ចសន្ទនាជាន់ខ្ពស់អំពីការកាត់បន្ថយភាពក្រីក្រចិន-អាហ្វ្រិកដែលរៀបចំនៅខែមិថុនា ឆ្នាំ២០១៧ នោះតំណាងនៃប្រទេសកុងហ្គោបានលើកសៀវភៅចិនមួយក្បាល"កាត់បន្ថយភាពក្រីក្រ" ហើយថ្លែងចំណាប់អារម្មណ៍របស់ខ្លួនថាសៀវភៅនេះមិនគ្រាន់តែបោះពុម្ពសម្រាប់ជនជាតិចិនប៉ុណ្ណោះទេ ហើយក៏ជាសៀវភៅមួយក្បាលដែលបោះពុម្ពសម្រាប់ប្រជាជនទ្វីបអាហ្វ្រិកព្រមទាំងប្រទេស និងប្រជាជនដែលកំពុងខិតខំរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រលើពិភពលោកទាំងមូលដែរ ។

បច្ចុប្បន្នប្រទេសចិនកំពុងរួមចំណែកយ៉ាងសកម្មក្នុងការដោះស្រាយបញ្ហាលំបាកផ្សេងៗលើពិភពលោកតាមរយៈការជំរុញការអភិវឌ្ឍរបស់ខ្លួន ហើយបានបង្ហាញពីស្មារតីទំនួលខុសត្រូវជាប្រទេសដ៏ធំមួយ ។ លើវិស័យអេកូ-បរិស្ថានប្រទេសចិនកំពុងខិតខំជំរុញការថែរក្សាបរិស្ថាន និងការកសាងអេកូ-អរិយធម៌ ។ លើវិស័យសិទ្ធិមនុស្សប្រទេសចិនប្រកាន់ខ្ជាប់នូវគោលការណ៍ដែលចាត់ទុកប្រជាជនជាស្នូលហើយចាត់ទុកគោលការណ៍នេះជាទស្សនៈស្នូលសម្រាប់ការអភិវឌ្ឍបុព្វហេតុសិទ្ធិមនុស្សចាត់ទុកសិទ្ធិអំពីការរស់នៅនិងសិទ្ធិអភិវឌ្ឍន៍ជាសិទ្ធិមូលដ្ឋានចម្បងរបស់មនុស្សហើយធ្វើការសម្របសម្រួលនិងជំរុញការអភិវឌ្ឍសិទ្ធិរបស់ប្រជាជនទាំងមូលលើវិស័យសេដ្ឋកិច្ចនយោបាយ សង្គម វប្បធម៌ និងបរិស្ថាន ។ លើវិស័យសេដ្ឋកិច្ចប្រទេសចិនបានរួមវិភាគទានជាង៣០ភាគរយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចលើពិភពលោកក្នុងរយៈពេលជាច្រើនឆ្នាំជាប់ៗគ្នា ហើយបានក្លាយទៅជាកម្លាំងរក្សាស្ថិរភាពនិងជាប្រភពកម្លាំងចលករសំខាន់សម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចលើពិភពលោក ។

បច្ចុប្បន្នការអភិវឌ្ឍន៍របស់ប្រទេសចិនកំពុងជំរុញឱ្យពិភពលោកដើរឆ្ពោះទៅមុខឥតឈប់ឈរហើយបានសបញ្ជាក់ឱ្យឃើញថា កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសចិន គឺជាកិច្ចខិតខំប្រឹងប្រែងរបស់មនុស្សជាតិទាំងមូល ចំណែកការអភិវឌ្ឍរបស់ប្រទេសចិន គឺជាកាលានុវត្តភាពសម្រាប់ពិភពលោកទាំងមូល ៕ **(កាសែតប្រជាជន)**

## ឯកឧត្តម ស៊ី ជីនភីង បកស្រាយពីគោល-ការណ៍អំពីការធ្វើដំណើរដោយឥតងាករេតាមមាគ៌ាអភិវឌ្ឍន៍ប្រកបដោយសន្តិភាព

សន្តិភាពជាក្តីសង្ឃឹមរួម និងជាគោលដៅចង់បានរបស់សង្គមមនុស្សជាតិ ។ បច្ចុប្បន្នសន្តិភាពនិងការអភិវឌ្ឍបានក្លាយទៅជាប្រធានបទសំខាន់នៃយុគសម័យលើពិភពលោក ប៉ុន្តែការគំរាមកំហែងសន្តិសុខដែលប្រទេសផ្សេងៗកំពុងប្រឈមមុខនោះកាន់តែមានភាពស្មុគស្មាញពីមួយថ្ងៃទៅមួយថ្ងៃហើយមិនអាចលុបចោលទាំងស្រុងនូវការគំរាមកំហែងនៃសង្គ្រាម ។ ជនជាតិចិនស្រឡាញ់សន្តិភាព ។ ប្រជាជនចិនយល់ដឹងច្បាស់ថាសន្តិភាពមានភាពថ្លៃថ្លា ។ ប្រទេសចិនប្រកាន់ខ្ជាប់នូវគោលការណ៍នៃការធ្វើដំណើរតាមមាគ៌ាអភិវឌ្ឍន៍ ដែលប្រកបដោយសន្តិភាព ហើយនឹងធ្វើជាអ្នកស្ថាបនាសន្តិភាពពិភពលោកអ្នករួមវិភាគទានក្នុងការអភិវឌ្ឍន៍ពិភពលោក និងជាអ្នកការពារសណ្តាប់ធ្នាប់អន្តរជាតិជានិច្ចកាល ៕

**(ដកស្រង់ចេញពីលិខិតអបអរសាទររបស់ឯកឧត្តមស៊ី ជីនភីង សម្រាប់ទិវាសន្តិភាពអន្តរជាតិប្រចាំឆ្នាំ ២០១៨)**

## ទិដ្ឋភាពថ្មីនៅមណ្ឌលទីឈីងគំនូរស្រស់ស្អាតជាងគេក្នុងតំបន់ជនជាតិទីបេត៍



ប្រជាជនមណ្ឌល ទីឈីងបង្កើតគំនូរដ៏ស្រស់ស្អាតអំពី ជីវភាពរស់នៅ ដែលប្រកបដោយ សុភមង្គល

ពាក្យថា "ទីឈីង" ក្នុងភាសាទីបេត៍ មានន័យថា "កន្លែងប្រកបដោយសិរីមង្គល"។ ក្នុងរយៈពេល៧០ឆ្នាំកន្លងទៅក្រោយពីបង្កើតសាធារណរដ្ឋប្រជាមានិតចិនរៀងមក មណ្ឌលស្វយ័តជនជាតិទីបេត៍ទីឈីងនៃខេត្តយូនណានបានត្រួសត្រាយផ្លូវអភិវឌ្ឍន៍ដ៏អស្ចារ្យមួយខ្សែដែលបានបង្ហាញពីសមិទ្ធផលអភិវឌ្ឍន៍សេដ្ឋកិច្ចលើខ្ពង់រាបថែរក្សាស្ថិរភាពក្នុងសង្គមរួមសាមគ្គីគ្នាគ្រប់ជនជាតិលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងកែលម្អអេកូ-បរិស្ថាន ។

ក្នុងរយៈពេល៧០ឆ្នាំកន្លងទៅនោះមណ្ឌលទីឈីងខិតខំជំរុញការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ។ សព្វថ្ងៃ ក្នុងមណ្ឌលទីឈីងមានផ្លូវថ្នល់ ៦៨៨៦ គីឡូម៉ែត្រ ត្រូវជា ៣២៧ដងនៃប្រវែងផ្លូវថ្នល់នៅពេលមណ្ឌលទីឈីងទើបត្រូវបង្កើតឡើងនៅឆ្នាំ១៩៥៧ ។ ការសាងសង់ផ្លូវនឹងអាចជំរុញការអភិវឌ្ឍវិស័យផ្សេងៗក្នុងសង្គម ។ នៅឆ្នាំ ២០១៨ ផលិតផលសរុបក្នុងតំបន់ទីឈីងបានកើនឡើង៣.២៨១ដងបើប្រៀបធៀបនឹងឆ្នាំ១៩៥២ ។

ជាពិសេសមណ្ឌលទីឈីងបានដើរតួនាទីឈានមុខនៅខេត្តយូនណានក្នុងការផ្តល់ការអប់រំឥតគិតថ្លៃរយៈពេល១៤ឆ្នាំ ។ រដ្ឋបាលមណ្ឌលទីឈីងខិតខំជំរុញការកាត់បន្ថយភាពក្រីក្រតាមរយៈការលើកទឹកចិត្តនិងបណ្តុះបណ្តាលប្រជាជន ។ គោលនយោបាយអំពីការអភិវឌ្ឍវិស័យអប់រំបានធ្វើឱ្យប្រជាជនកាន់តែមានជំនឿចិត្តក្នុងការស្វែងរកជីវភាពរស់នៅដ៏ល្អបវរ ។ សព្វថ្ងៃរដ្ឋបាលមណ្ឌលទីឈីងបានកាត់បន្ថយភូមិក្រីក្រចំនួន១០៧ (សរុបមានភូមិក្រីក្រចំនួន១៤៧) ចំណែកអត្រានៃការកើតមានបញ្ហាក្រីក្របានធ្លាក់ចុះពី២៤៤ភាគរយនៅឆ្នាំ ២០១៥ ដល់កម្រិត ២,៥៧ ភាគរយនាពេលបច្ចុប្បន្ន ។

នៅឆ្នាំ២០១៨ មណ្ឌលទីឈីងបានទទួលភ្ញៀវទេសចរ២៤,១លាននាក់ ហើយបានចាត់ទុកការការពារអេកូ-បរិស្ថានជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍនៃវិស័យទេសចរណ៍ ។ មណ្ឌលទីឈីងបានបង្កើតតំបន់អភិរក្ស ធម្មជាតិថ្នាក់ជាតិ១ និង តំបន់អភិរក្សធម្មជាតិថ្នាក់ខេត្តចំនួន៣ដែលមានទំហំសរុបជាង ៣២លានហិកតា ៕ **ដោយចាំងហ្វាន**

## ពិព័រណ៍អំពីកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គ ប្រចាំឆ្នាំ ២០១៩ នឹងរៀបចំក្នុងក្រុងគុនមីងនៅខែវិច្ឆិកាខាងមុខ

តាមប្រភពព័ត៌មានពីគណៈកម្មាធិការរៀបចំពិព័រណ៍សហប្រតិបត្តិការទន្លេឡានឆាង-មេគង្គប្រចាំ ឆ្នាំ ២០១៩បានឱ្យដឹងថា ពិព័រណ៍សហប្រតិបត្តិការទន្លេឡានឆាង-មេគង្គប្រចាំឆ្នាំ២០១៩នឹងត្រូវរៀបចំនៅ មជ្ឈមណ្ឌលសន្និសីទនិងពិព័រណ៍អន្តរជាតិក្រុងគុនមីងក្នុងអំឡុងពេលពីថ្ងៃទី ២១ដល់ទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

ពិព័រណ៍នេះ នឹងត្រូវរៀបចំក្រោមប្រធានបទ"រួមគ្នាផឹកទឹកទន្លេតែមួយធ្វើកិច្ចសហប្រតិបត្តិការដើម្បីជំរុញការអភិវឌ្ឍរួមគ្នា"ហើយមានកម្មវិធីពិព័រណ៍មួយនិងវេទិកាមួយ ។ តំបន់ពិព័រណ៍មានទំហំ៥ម៉ឺនម៉ែត្រការ៉េនិងស្តង់ពិព័រណ៍ចំនួន២.០០០ដែលអាចគ្របដណ្តប់លើវិស័យវិនិយោគពាណិជ្ជកម្ម ធនធានមនុស្សវប្បធម៌ ទេសចរណ៍ ផលិតផលពិសេសនៃប្រទេទន្លេឡាន-ឆាង-មេគង្គនិងផលិតផលល្បីអន្តរជាតិជាដើម ។ តាមការព្យាករណ៍ប្រទេសចំនួន១៨នឹងចូលរួមក្នុងពិព័រណ៍នេះ ។ ស្តង់ពិព័រណ៍បរទេសមានចំនួនស្មើនឹង ៣៥ភាគរយ ។ ក្រៅពីនេះវេទិកាស្តីពីកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គបឹងទានឈឺ លើកទី៤នឹងត្រូវរៀបចំឡើងក្នុងឱកាសពិព័រណ៍នេះក្រោមប្រធានបទ"រួមគ្នាបង្កើតវេទិកាថ្មីដើម្បីជំរុញការអភិវឌ្ឍន៍ថ្មី"។ វេទិកានេះរួមមានសកម្មភាពច្រើនដូចជាកិច្ចប្រជុំស្តីពីការវិនិយោគចិន-ឡាវ កិច្ចប្រជុំស្តីពីការវិនិយោគចិន-កម្ពុជានិងវេទិកាស្តីពីការផ្តល់សេវាកម្មច្នៃប្រឌិតផ្នែកធនធានមនុស្សតំបន់អាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូងជាដើម ។

គួរបញ្ជាក់ថា ពិព័រណ៍នេះនឹងផ្តល់អាទិភាព ដល់ការអភិវឌ្ឍ ធនធានមនុស្សអន្តរជាតូបនីយកម្មហើយនឹងរៀបចំ"ទិវាការងារនៅក្រៅប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍និង អាស៊ីខាងត្បូង"តាមរយៈវេទិកាស្តីពីការផ្តល់សេវាកម្មច្នៃប្រឌិតផ្នែកធនធានមនុស្សតំបន់អាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង ។ តាមការព្យាករណ៍ព័ត៌មានអំពីការជ្រើសរើសបុគ្គលិកការងារ និងការបង្កើតមុខជំនួញថ្មីចំនួនជាងមួយម៉ឺននឹងត្រូវប្រកាសក្នុងពិព័រណ៍នេះ ៕

**ដោយ អ៊ូភីង**

## ពិធីអបអរសាទរខួបលើកទី៧០នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិនបានរៀបចំក្នុងក្រុងប៉េកាំង

នៅថ្ងៃទី ១ ខែតុលា ពិធីអបអរសាទរខួបលើកទី៧០ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន បានរៀបចំយ៉ាងឧឡារិក នៅទីធ្លាធានអានមិន ក្នុងក្រុងប៉េកាំង ។ ឯកឧត្តម ស៊ី-ជីនភីង អគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន ប្រធានាធិបតីចិននិងជាប្រធានគណៈកម្មាធិការយោធាមជ្ឈិមបក្សកុម្មុយនិស្តចិន បានអញ្ជើញចូលរួមនិងថ្លែងសុន្ទរកថាសំខាន់ក្នុងពិធីនេះ ។ ក្រៅពីនេះ នៅមានពិធីត្រួតពលនិងហែក្បួនរបស់មហាជនដ៏អធិកអធម ៕

